COUNT US IN 2020

There's Power In Being Counted

ASIAN AMERICANS ADVANCING JUSTICE

COUNTUSIN2020.ORG

# តើខ្ញុំឆ្លើយតបទៅនឹងជំរឿនឆ្នាំ2020 ដោយរបៀបណា ហើយតើគេសួរខ្ញុំពីអ្វីខ្លះ?

*មានសំណួរមែនទេ? សូមហៅទូរស័ព្ទទៅកាន់ខ្សែទូរស័ព្ទទាន់ហេតុការណ៍ ផ្នែកជំរឿនរបស់យើងតាមលេខ 844-2020-API សម្រាប់ជំនួយគាំទ្រជាភាសាអង់គ្លេស និងភាសាដទៃផ្សេងទៀត។ សូមចូលមើលគេហទំព័រ www.CountUsIn2020.org/hotline សម្រាប់ព័ត៍មានបន្ថែម។*

ជំរឿនឆ្នាំ2020 នឹងរាប់បញ្ចូលចំនួនប្រជាជនទាំងអស់ដែលរស់នៅក្នុងសហរដ្ឋអាមេរិក។ ជំរឿនគឺជាកម្រងសំណួរខ្លីមួយដែលសួរព័ត៍មានមូលដ្ឋានអំពីគ្រួសាររបស់អ្នក និង ចំនួនសមាជិកដែលរស់នៅក្នុងនោះ។ ការឆ្លើយតបរបស់អ្នកគឺជាការសម្ងាត់ ហើយនឹងមិនត្រូវបានចែករំលែកជាមួយភ្នាក់ងាររដ្ឋាភិបាលដទៃទៀត រួមមានការអនុវត្តន៍អន្តោប្រវេសន៍នគរបាល ឬ អាផ្ទះលំនៅដ្ឋានជាដើម។ រដ្ឋាភិបាលប្រើប្រាស់ចំនួនប្រជាជនដើម្បីបែងចែកអ្នកតំណាងនយោបាយ និង កំណត់ការចំណាយធនធាន។

## តើខ្ញុំឆ្លើយតបទៅនឹងជំរឿនឆ្នាំ2020 ដោយរបៀបណា?

នៅខែមីនា ឆ្នាំ2020 ការិយាល័យជំរឿននឹងផ្ញើព័ត៍មានទៅកាន់គ្រួសារនីមួយៗ ក្នុងគោលបំណងអញ្ជើញពួកគេឱ្យឆ្លើយតបទៅនឹងជំរឿន។ មានវិធីបីយ៉ាងក្នុងការចូលរួម៖

| | |
|---|---|
| **អនឡាញ** | លើកដំបូង អ្នកអាចបំពេញសំណុំបែបបទជំរឿនរបស់អ្នកតាមប្រព័ន្ធអ៊ីនធឺណិតបាន។ គ្រួសារភាគច្រើននឹងទទួលបានលិខិតមួយច្បាប់ដែលស្នើសុំអោយពួកគេឆ្លើយតបតាមរយៈប្រព័ន្ធអ៊ីនធឺណែតដោយមានលេខសម្គាល់គ្រួសារតែមួយគត់ និង គេហទំព័រផ្លូវការរបស់ការិយាល័យជំរឿន។<br><br>*សំណុំបែបបទឆ្លើយតបដោយខ្លួនឯងតាមប្រព័ន្ធអ៊ីនធឺណិតមានផ្តល់ជូនសម្រាប់ 12 ភាសាដែលមិនមែនជាភាសាអង់គ្លេស រួមមានភាសាចិន (សាមញ្ញ) ភាសាជប៉ុន ភាសាកូរ៉េតាកាឡុក និង ភាសាវៀតណាម។* |
| **ទូរស័ព្ទ** | អ្នកអាចហៅទៅកាន់ទូរស័ព្ទជំនួយដើម្បីសាកសួរ និង ឆ្លើយតបទៅនឹងជំរឿនតាមទូរស័ព្ទ។<br><br>*ការគាំទ្រតាមទូរស័ព្ទមានផ្តល់ជូន ជាភាសាអង់គ្លេស និង 12 ភាសាទៀតដែលមិនមែនជាភាសាអង់គ្លេស រួមមានភាសាចិន (ភាសាចិនកុកងឺ និង កាតាំង) ភាសាជប៉ុន ភាសាកូរ៉េភាសា តាកាឡុក និងភាសាវៀតណាម។ អ្នកហៅចូលអាចទទួលបានព័ត៍មានបន្ថែមស្តីពីការធ្វើជំរឿន សួរសំណួរពាក់ព័ន្ធផ្សេងៗ និង ផ្តល់ចម្លើយបែបបទជំរឿនរបស់ពួកគេតាមទូរស័ព្ទតាមរយៈប្រព័ន្ធទូរស័ព្ទឥតគិតថ្លៃរបស់ការិយាល័យជំរឿនសម្រាប់ភាសានីមួយៗ។* |
| **ក្រដាស** | អ្នកអាចឆ្លើយតបជាទម្រង់ក្រដាស។ ផ្ទះមួយចំនួន - ប្រហែលមួយក្នុងប្រាំផ្ទះ - នឹងទទួលបានបែបបទក្រដាសមួយច្បាប់នៅក្នុងការផ្ញើតាមប្រៃសណីយ៍ដំបូង។ អ្នករាល់គ្នានឹងទទួលបានទម្រង់បែបបទក្រដាសនៅត្រឹមការផ្ញើតាមប្រៃសណីយ៍លើកទីបួន។<br><br>*ទម្រង់ជាក្រដាសមានផ្តល់ជូនតែក្នុង ភាសាអង់គ្លេស និង អេស្ប៉ាញប៉ុណ្ណោះ។* |

## តើខ្ញុំឆ្លើយតបទៅនឹងជំរឿននៅពេលណា?

ការិយាល័យជំរឿននឹងផ្ញើព័ត៌មានជាច្រើនលើកដើម្បីលើកទឹកចិត្តអោយប្រជាជនឆ្លើយតបៈ

| | |
|---|---|
| ថ្ងៃទី 12 - ថ្ងៃទី 20 ខែមិនា | ការិយាល័យជំរឿននឹងផ្ញើលិខិតអញ្ជើញទៅកាន់គ្រួសារនីមួយៗដើម្បីឆ្លើយតបតាមរយៈការផ្ញើសំបុត្របិទងដាច់ដោយឡែកពីគ្នា។ |
| ថ្ងៃទី 16 - ថ្ងៃទី 24 ខែមិនា | គ្រួសារដែលមិនបានឆ្លើយតបនឹងទទួលបានសំបុត្ររំលឹក។ |
| ថ្ងៃទី 26 មិនា - ថ្ងៃទី 3 ខែមេសា | គ្រួសារដែលមិនបានឆ្លើយតបនឹងទទួលបានសំបុត្ររំលឹក។ |
| ថ្ងៃទី 8 - ថ្ងៃទី 16 ខែមេសា | គ្រួសារដែលមិនបានឆ្លើយតបនឹងទទួលបានសំបុត្ររំលឹក និងទម្រង់បែបបទជាក្រដាស។ |
| ថ្ងៃទី 20 - ថ្ងៃទី 27 ខែមេសា | សំបុត្ររំលឹកលើកចុងក្រោយនឹងត្រូវបានផ្ញើជូនផងដែរ។ |
| ថ្ងៃទី 13 ខែឧសភា | បុគ្គលិកការិយាល័យជំរឿននឹងចាប់ផ្តើមចុះទៅសួរសុខទុកចំពោះគ្រួសារណាដែលមិនទាន់បានឆ្លើយតប។ |

## តើជំរឿននៅឆ្នាំ2020 នឹងសួរខ្ញុំពីអ្វីខ្លះ?

ការធ្វើជំរឿនឆ្នាំ2020 ត្រូវការចំណាយពេលតែប៉ុន្មាននាទីប៉ុណ្ណោះដើម្បីបំពេញ និង សួរសំណួរខាងក្រោម។

**ជំរឿននៅឆ្នាំ2020 នឹងសួរអំពីគ្រួសាររបស់អ្នក។**

| | |
|---|---|
| ចំនួនមនុស្សដែលរស់នៅ ឬស្នាក់<br>នៅក្នុងអាស័យដ្ឋានរបស់អ្នកនៅថ្ងៃទី1 ខែមេសា។ | *រួមបញ្ចូលសមាជិកគ្រប់គ្នាដែលរស់នៅក្នុងផ្ទះរបស់អ្នក ទោះបីពួកគេពុំជាប់សាច់ឈាមជាមួយនឹងអ្នកក្តី។*<br>*ការធ្វើជំរឿនរាប់មនុស្សទាំងអស់នៅសហរដ្ឋអាមេរិករាប់បញ្ចូលទាំងកុមារតូចៗ ប្រជាពលរដ្ឋដែលមិនទាន់មានសញ្ជាតិ អ្នកជួលផ្ទះ - គ្រប់គ្នា។* |
| តើអ្នកមានផ្ទះខ្លួនឯង ឬជួលផ្ទះគេ? | *សូមឆ្លើយថាអ្នកជាម្ចាស់ផ្ទះ ឬ ជួលផ្ទះគេ។* |
| លេខទូរស័ព្ទ | *ការិយាល័យជំរឿននឹងប្រើលេខទូរស័ព្ទរបស់អ្នកប្រសិនជាចាំបាច់សម្រាប់អាជីវកម្មរបស់ការិយាល័យជំរឿនផ្លូវការ។* |

**ជំរឿននៅឆ្នាំ 2020 នឹងសួរអំពីបុគ្គលម្នាក់ៗដែលរស់នៅក្នុងគ្រួសាររបស់អ្នក។**

| | |
|---|---|
| ឈ្មោះ អាយុ ថ្ងៃខែឆ្នាំកំណើត និង ភេទ | *បញ្ចូលឈ្មោះ អាយុ និង ថ្ងៃខែឆ្នាំកំណើតរបស់សមាជិកម្នាក់ៗ។ សូមកត់សម្គាល់ថា សម្រាប់ភេទ ការិយាល័យជំរឿនផ្តល់ជម្រើសតែ ប្រុស និង ស្រី តែប៉ុណ្ណោះ។* |
| ទំនាក់ទំនងជាមួយបុគ្គលដែលបំពេញសំណុំបែបបទ | *មានបញ្ជីទំនាក់ទំនងដែលអ្នកអាចជ្រើសរើសបានរួមទាំង ប្តី ប្រពន្ធ (ភេទដូចគ្នា ឬ ផ្ទុយគ្នា)*<br>*បងប្អូនប្រុស ឬ បងប្អូនស្រី ឪពុក ម្តាយ មិត្តរួមផ្ទាក់ ឬ អ្នកដទៃ។* |
| ជាតិសាសន៍ | *អ្នកអាចជ្រើសរើសយកសញ្ជាតិមួយ ឬ ច្រើនជាងនេះ។ ប្រសិនបើអ្នកជាកូនកាត់ច្រើនសញ្ជាតិ អ្នកអាចពិនិត្យមើលប្រអប់តែមួយ ឬ ប្រអប់ច្រើន សម្រាប់ក្រុមពូជសាសន៍របស់អ្នកហើយសរសេរព័ត៌មានលម្អិតបន្ថែមទៀតអំពីជាតិសាសន៍របស់អ្នក។* |

| | |
|---|---|
| | *មិនមានជាតិសាសន៍ទាំងអស់សុទ្ធតែត្រូវបានរាយបញ្ជី សម្រាប់ជ្រើសរើសឡើយ។ ប្រសិនបើក្រុមជាតិសាសន៍របស់អ្នក មិនមានក្នុងបញ្ជីទេ អ្នកអាចសរសេរលម្អិតបន្ថែមទៀតអំពីប្រវត្តិ ជាតិសាសន៍របស់អ្នកបាន។* |
| ប្រភពដើមជនជាតិអេស្ប៉ាញ | *ផ្នែកនេះនឹងសួរថាតើ អ្នកជាជនជាតិនិយាយភាសាអេស្ប៉ាញ ឬ ឡាតាំង។ នេះត្រូវបានចាត់ទុកថាជាជាតិសាសន៍មិនមែនជា ពូជសាសន៍ទេ។*<br>*គូសយកជម្រើសនេះបន្ថែមចំពោះប្រអប់ជាតិសាសន៍។* |

ជំរឿនឆ្នាំ 2020 នឹងមិនសួរអ្នកនូវសំណួរអំពីភាពជាប្រជាជនឡើយ។

ប្រសិនបើមានមនុស្សច្រើនជាង 6 នាក់រស់នៅក្នុងផ្ទះរបស់អ្នក អ្នកគ្រាន់តែផ្តល់ព័ត៌មាន មូលដ្ឋានរបស់សមាជិកទី7 និង បន្ទាប់បានហើយ។ ព័ត៌មានមូលដ្ឋានមានដូចជា ឈ្មោះ អាយុ ថ្ងៃខែឆ្នាំកំណើត ភេទ ជាតិសាសន៍ និង ទំនាក់ទំនងបុគ្គលនោះជាមួយបុគ្គលដែលបំពេញ សំណុំបែបបទ។

## តើអ្វីខ្លះដែលជំរឿននៅឆ្នាំ 2020 នឹងមិនសួរខ្ញុំ?

**ទម្រង់បែបបទនឹងមិនសួរអ្នកអំពីអន្តោប្រវេសន៍ ឬស្ថានភាពនៃភាពជាប្រជាជនរបស់អ្នកឡើយ ។ ទម្រង់ក៏មិនសួរអំពីលេខសន្តិសុខសង្គម (SSN) របស់អ្នកដែរ។**

## តើខ្ញុំត្រូវតែឆ្លើយនឹងសំណួរទាំងអស់ឬទេ?

ច្បាប់សហព័ន្ធតម្រូវឱ្យប្រជាជនគ្រប់រូបចូលរួមក្នុងជំរឿន និង ឆ្លើយគ្រប់សំណួរទាំងអស់។ អ្នក ឆ្លើយសំណួរដែលផ្តល់ឈ្មោះ និង អាស័យដ្ឋានរបស់ពួកគេ ប៉ុន្តែរំលងសំណួរមួយ ឬ ពីរក៏នៅតែត្រូវបាន រាប់បញ្ចូលដែរ។ ប្រសិនបើអ្នករំលងសំណួរជាច្រើន ឬ មិនឆ្លើយសំណួរជំរឿនទាល់តែសោះ បុគ្គលិកជំរឿនអាចនឹងចុះទៅផ្ទះរបស់អ្នកដើម្បីទទួលបានព័ត៌មានដែលនូវខ្វះខាត។ ឆ្លើយសំណួរ ទាំងអស់ដោយស្មោះត្រង់ កុំកុហកពេលឆ្លើយតបទៅនឹងជំរឿន។

## តើការឆ្លើយតបរបស់ខ្ញុំជាការសម្ងាត់ឬទេ? តើការឆ្លើយតបទៅនឹងការធ្វើជំរឿនឆ្នាំ 2020 អាចធ្វើឱ្យប៉ះពាល់ដល់ខ្ញុំដែរទេ?

- <u>ការសម្ងាត់៖</u> ព័ត៌មានជំរឿនទាំងអស់គឺជាការសម្ងាត់។ តាមច្បាប់ ការិយាល័យជំរឿន មិនអាចចែករំលែកព័ត៌មានរបស់បុគ្គលណាម្នាក់ជាមួយមនុស្សម្នាក់ទៀតបានទេ ដែលក្នុងនោះរួមមានទាំង អាជ្ញាធរអន្តោប្រវេសន៍ ភ្នាក់ងាររដ្ឋាភិបាលដទៃទៀត និង សាធារណជនជា ដើម។ ច្បាប់របស់សហព័ន្ធមានការធានាការសម្ងាត់យ៉ាងរឹងមាំបំផុត សម្រាប់ទិន្នន័យជំរឿន និង ការពារព័ត៌មានរបស់អ្នក។
- <u>ការពិន័យ៖</u> បុគ្គលិកការិយាល័យជំរឿនទាំងអស់ដែលមានលទ្ធភាពប្រើប្រាស់ទិន្នន័យរបស់អ្នកត្រូវ ស្បថអស់មួយជីវិតដើម្បីការពារព័ត៌មានរបស់អ្នក។ ប្រសិនបើនរណាម្នាក់បំពានច្បាប់នេះ វានឹងក្លាយជាបទឧក្រិដ្ឋរបស់សហព័ន្ធ អាចទទួលការពិន័យធ្ងន់ធ្ងរ រួមទាំងការផ្តន្ទាទោសដាក់ ពន្ធនាគារសហព័ន្ធរហូតដល់ 5 ឆ្នាំ ពិន័យជាប្រាក់រហូតដល់ $250,000 ឬ ទាំងពីរករណីក៏ថាបាន។
- <u>ការការពារទិន្នន័យ៖</u> លើសពីនេះទៀត ការឆ្លើយតបដែលប្រមូលបានដោយការិយាល័យ ជំរឿននឹងត្រូវបានប្រើប្រាស់សម្រាប់តែគោលបំណងស្ថិតិតែប៉ុណ្ណោះ។ ការិយាល័យជំរឿន ធ្វើការបោះពុម្ពតែស្ថិតិសរុបប៉ុណ្ណោះ ហើយអាចមិនបោះផ្សាយព័ត៌មានដែលនឹងកំណត់ អត្តសញ្ញាណបុគ្គលណាម្នាក់ អាជីវកម្ម ឬ អង្គការណាមួយឡើយ។ ទីភ្នាក់ងាររដ្ឋាភិបាល សហព័ន្ធរដ្ឋ និង រដ្ឋត្រូវបានហាមឃាត់មិនឱ្យប្រើ ទិន្នន័យស្ថិតិដែលបង្កើតឡើងដោយ ការិយាល័យជំរឿនដែលអាចធ្វើឱ្យប៉ះពាល់ ដល់បុគ្គលណាម្នាក់ដែលបានឆ្លើយតបទៅនឹង ជំរឿនឡើយ។

## ចុះបើខ្ញុំត្រូវការជំនួយភាសាដើម្បីបំពេញជំរឿនឆ្នាំ 2020?

**អនឡាញ៖** សំណុំបែបបទឆ្លើយតបដោយខ្លួនឯងតាមប្រព័ន្ធអ៊ិនធឺណិតមានផ្តល់ជូនក្នុង 12 ភាសាដែលមិនមែនជាភាសាអង់គ្លេស រួមទាំងភាសាចិន (សាមញ្ញ) ជប៉ុន កូរ៉េ តាកាឡុក និង ភាសាវៀតណាម។

**ទូរស័ព្ទ៖** ការគាំទ្រតាមទូរស័ព្ទត្រូវបានផ្តល់ជូនជាភាសាអង់គ្លេស និង 12 ភាសាទៀតដែល មិនមែនជាភាសាអង់គ្លេស រួមទាំងភាសាចិន (ភាសាចិនកុកងឺ និង កាតាំង) ភាសាជប៉ុន ភាសាកូរ៉េ ភាសាតាកាឡុក និង ភាសាវៀតណាម។ តាមរយៈលេខទូរស័ព្ទឥតគិតថ្លៃរបស់ការិយាល័យជំរឿនសម្រាប់ភាសានីមួយៗ អ្នកហៅចូលអាចទទួលបានព័ត៌មានបន្ថែមស្តីពី ការធ្វើជំរឿន សួរសំណួរពាក់ព័ន្ធផ្សេងៗ និង ផ្តល់ចម្លើយដល់បែបបទធ្វើជំរឿនតាមទូរស័ព្ទ។

**ក្រដាស៖** ទម្រង់បែបបទជាក្រដាសមានផ្តល់ជូនសម្រាប់ ភាសាអង់គ្លេស និង អេស្ប៉ាញ។

**ធនធានជំនួយភាសា៖** ការិយាល័យជំរឿនបានបង្កើតសទ្ទានុក្រមភាសា ប័ណ្ណសម្គាល់ភាសា និង មគ្គុទេសក៍ភាសាជាភាសាមិនមែនអង់គ្លេសចំនួន 59 ភាសាដែលអាចរកបាននៅលើគេហទំព័រ www.2020census.gov/en/languages.html។

*អ្នកអាចស្វែងរកធនធានបន្ថែមអំពីជំរឿន រួមមានទាំងក្រដាស Fact សម្រាប់សមាជិកសហគមន៍ និង អង្គការផ្សេងៗតាមសហគមន៍តាមរយៈ www.CountUsIn2020.org/resources។*